**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គជអប
NCDD

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប**
**ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**លេខាធិការដ្ឋាន គ.ជ.អ.ប**

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំលើកទី១១ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់បណ្តាញសារព័តិមានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា គ.ជ.អ.ប នឹងរៀបចំកិច្ចប្រជុំលើកទី១១ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលប្រព្រឹត្តទៅក្នុងពិធីបើក និងបិទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប ។**

កិច្ចប្រជុំនេះ មានរបៀបវារៈដូចខាងក្រោម៖

១. ការពិភាក្សា និងអនុម័តលើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំលើកទី១០ របស់ គ.ជ.អ.ប

២. សេចក្តីរាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥

៣. ការពិភាក្សាអំពីកិច្ចដំណើរការផ្ទេរមុខងារ និងធនធានពីក្រសួង ស្ថាប័នទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

៤. ការពិភាក្សា និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ការពិភាក្សា និងអនុម័តលើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ គ.ជ.អ.ប

៦. បញ្ហាផ្សេងៗស្តីពី៖

-របាយការណ៍សង្ខេបស្តីពីវឌ្ឍនភាពនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ

-ការផ្ទេរមុខងារទីក្រុងពីក្រសួង ស្ថាប័នទៅឱ្យរាជធានី

-វិសោធនកម្មច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

សិក្ខាសាលានឹងមានការចូលរួមពីតំណាងក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលជាសមាជិក គ.ជ.អ.ប តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងក្រសួង ស្ថាប័នអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប្រធានក្រុមប្រឹក្សា អភិបាលរាជធានី ខេត្ត ក្រុង ស្រុក និងមន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប សរុបប្រមាណជា១២០ រូប ។

**ទីកន្លែង:** សាលប្រជុំក្រសួងមហាផ្ទៃ (អគារ S) មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ
**ពេលវេលា:** ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ចាប់ពីម៉ោង ៧:៣០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីដែលជាអ្នកសារព័ត៌មាន ចូលរួមយកព័ត៌មានកុំបីខាន ។

*ព័ត៌មានបន្ថែម សូមទំនាក់ទំនងលេខាធិការដ្ឋាន គ.ជ.អ.ប*
*លេខទូរស័ព្ទ ០៧៨ ៥៧៥ ៧៧៥*
*E-mail: tharith@ncdd.gov.kh*
*Website: www.ncdd.gov.kh*